ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ១១៥ សរណន.កសក

# សារាចរណែនាំ
## ស្ដីពី
## ការចាត់វិធានការពង្រឹងការគ្រប់គ្រងអាជីវកម្មសត្វ និងជលផល

កន្លងមក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកត់សម្គាល់ឃើញថា មានភាពផ្ដាច់មុខលើការធ្វើអាជីវកម្មសត្តឃាតដ្ឋាន ការឃុបឃិតគ្នាក្នុងចំណោមអាជីវករពិឃាតសត្វ អ្នកលក់ដុំនិងលក់រាយធ្វើការកំណត់ថ្លៃ និងភាពផ្ដាច់មុខលើការធ្វើអាជីវកម្ម នាំចូល ចែកចាយ ឬការដឹកជញ្ជូនផលនិងផលិតផលជលផល ព្រមទាំងការអនុវត្តច្បាប់ ការគ្រប់គ្រងរបស់អាជ្ញាធរមានសមត្ថកិច្ចនៅមានកម្រិត។ កត្តាទាំងអស់នេះ បង្កឱ្យមានការបូកថ្លៃបន្ថែមខ្ពស់នៅគ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្មនិងអាជីវកម្ម និងបានធ្វើឱ្យមានអត្រាអតិផរណាម្ហូបអាហារកើនឡើង ប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

ក្នុងទិសដៅពង្រឹងការគ្រប់គ្រងការធ្វើអាជីវកម្មសត្វ និងផលិតផលជលផលឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយអនុលោមតាមលក្ខខណ្ឌបច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្តជាធរមាននោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចដាក់ចេញនូវវិធានការចាំបាច់មួយចំនួនដូចខាងក្រោម៖

**ក- សម្រាប់ការធ្វើអាជីវកម្មសត្វ**

១-បំបែកភាពផ្ដាច់មុខនៃអាជីវកម្មសត្តឃាតដ្ឋាន និងលុបបំបាត់ការឃុបឃិតគ្នាក្នុងការធ្វើអាជីវកម្មពិឃាតសត្វ ដោយបើកទូលាយឱ្យមានការចូលមកវិនិយោគបន្ថែមដោយសេរីលើអាជីវកម្មសត្តឃាតដ្ឋាន ប៉ុន្តែត្រូវគោរពតាមគោលការណ៍បច្ចេកទេសដូចមានចែងក្នុងអនុក្រឹត្យលេខ១០៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្ដីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ និងត្រូវបំពេញកាតព្វកិច្ចបង់ពន្ធ បង់ភាសីតាមច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន។ វិធានការនេះត្រូវអនុវត្តដូចតទៅ៖

- បង្កើនចំនួនសត្តឃាតដ្ឋានតាមក្រុង ស្រុក ដោយអនុញ្ញាតឱ្យមានការវិនិយោគបន្ថែម និងមិនកំណត់ដែនអាជីវកម្មសត្តឃាតដ្ឋាន ដែនអាជីវកម្មពិឃាតសត្វ និងតំបន់ចែកចាយសាច់ ឬផលិតផលសត្វ
- វិនិយោគិនត្រូវបានអនុញ្ញាតឱ្យពង្រីកអាជីវកម្មផ្ទាល់ខ្លួន ប៉ុន្តែមិនអនុញ្ញាតឱ្យលក់ ឬផ្ដល់សិទ្ធិបន្តទៅអ្នកដទៃ ពោលគឺមិនអនុញ្ញាតឱ្យលក់អាជ្ញាប័ណ្ណដែលដេញបានបន្តទៅឱ្យអ្នកផ្សេងឡើយ
- ពង្រឹងការអនុវត្តដោយតម្រូវឱ្យមានការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានស្ដីពីការវិនិយោគ និងការដេញថ្លៃទីតាំងសត្តឃាតដ្ឋានរបស់រដ្ឋឱ្យបានទូលំទូលាយប្រកបដោយតម្លាភាព
- ជំរុញការវិនិយោគឯកជនដែលបង្កើតសត្តឃាតដ្ឋានថ្មី ដោយមិនតម្រូវឱ្យផ្ទេរមកជាកម្មសិទ្ធិរបស់រដ្ឋ លើកលែងតែការវិនិយោគលើទីតាំងរបស់រដ្ឋ។ សម្រាប់គម្រោងអាជីវកម្មសត្តឃាតដ្ឋានដែលទទួលបានការអនុញ្ញាត និងចុះកិច្ចសន្យារួចហើយ ស្នើទុកឱ្យដំណើរការជាធម្មតាសិន ដោយខិតខំរកវិធីដោះស្រាយទៅតាមទិដ្ឋភាពជាក់ស្ដែងនៃករណីនីមួយៗ។ ជាមួយនេះ ស្នើជំរុញលើកទឹកចិត្តផងដែរដល់សមាគម ក្រុមហ៊ុន ឬអ្នកចិញ្ចឹមជ្រូក/គោ ឱ្យធ្វើការវិនិយោគបើកអាជីវកម្មសត្តឃាតដ្ឋានដោយខ្លួនឯងដោយគោរពទៅតាមច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន ដូចអ្នកធ្វើអាជីវកម្មសត្តឃាតដ្ឋានដទៃទៀត
- អនុញ្ញាតឱ្យមានសត្តឃាតដ្ឋានតាមមូលដ្ឋាន (ឃុំ/សង្កាត់) សម្រាប់ពិឃាតសត្វ ផ្គត់ផ្គង់សាច់នៅតាមមូលដ្ឋានផ្ទាល់។ ទន្ទឹមនឹងនេះ ស្នើជំរុញឱ្យសត្តឃាតដ្ឋានតូចៗនៅតាមឃុំ/សង្កាត់ មកចុះបញ្ជីក្នុងប្រព័ន្ធផ្លូវការ ដោយទុកពេលវេលាសមស្របឱ្យអាជីវករ ម្ចាស់សត្តឃាតដ្ឋានទាំងនេះ (៣ ទៅ ៥ឆ្នាំ) ដើម្បីរៀបចំ

បានពេញលេញទៅតាមបទដ្ឋានបច្ចេកទេសអនាម័យ (ស្តង់ដារអប្បបរមា) និងគោរពទៅតាមច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន។ ជាមួយនេះផងដែរ តម្រូវឱ្យអាជ្ញាធរភូមិឃុំ សង្កាត់ ស្រុក ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត បញ្ជាក់ប្រវត្តិរូប និងផ្តល់អាជ្ញាប័ណ្ណអាជីវកម្មពិឃាតសត្វដោយស្វ័យប្រវត្តិទៅអាជីវករទាំងអស់ដែលបានដាក់ពាក្យស្នើសុំ។

២-ពង្រឹងការត្រួតពិនិត្យអនាម័យសត្វ និងចរាចរណ៍សត្វនៅប្រភពដើមទីនិងចុងទី ដោយជំរុញការអនុវត្តគោលការណ៍ចត្តាឡីស័ក និងគ្រប់គ្រងហានិភ័យជំងឺសត្វរាតត្បាត និងជំងឺស៊ុយណូស។

៣-ជំរុញលើកទឹកចិត្តឱ្យអាជីវករលក់ដុំ និងលក់រាយដាក់ស្លាកសញ្ញាផលិតផលរបស់ខ្លួន ដោយបញ្ជាក់ពីប្រភពផលិតផលសាច់ (ជ្រូក គោ ក្របី មាន់ និងទា) នៅលើទីផ្សារដោយដាក់តម្លៃ និងផ្តល់ព័ត៌មានពេញលេញដល់អ្នកប្រើប្រាស់ ចៀសវាងការកេងបន្លំលើប្រភព និងប្រភេទផលិតផលសត្វពីសំណាក់អាជីវករចំពោះអ្នកប្រើប្រាស់ដែលអាចនឹងរួមចំណែកកែសម្រួលថ្លៃនៅលើទីផ្សារទៅតាមកម្រិតនៃផលិតផល។

**ខ- សម្រាប់ការធ្វើអាជីវកម្មផល និងផលិតផលជលផល**

១-លុបបំបាត់សិទ្ធិផ្តាច់មុខលើការនាំចូលផលនិងផលិតផលជលផល ដោយបើកឱកាសឱ្យមានការប្រកួតប្រជែងពេញលេញដល់ក្រុមហ៊ុននាំចូល (ថ្មី-ចាស់ និងតូច-ធំ) នៅតាមច្រកព្រំដែន ព្រមទាំងលុបបំបាត់ការលក់អាជ្ញាប័ណ្ណបន្ត ដើម្បីធានាបានថាក្រុមហ៊ុនទាំងអស់ដែលមានបំណងធ្វើអាជីវកម្មមានលទ្ធភាពនាំចូលផល និងផលិតផលជលផល ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុកដែលកំពុងខ្វះខាតជាក់ស្តែង។

២-សហការឱ្យបានល្អប្រសើរជាមួយស្ថាប័នពាក់ព័ន្ធក្នុងការពង្រឹងការអនុវត្តនីតិវិធីវិនិយោគលើមជ្ឈមណ្ឌលបែងចែកផលនេសាទ និងលុបបំបាត់ការវិនិយោគផ្តាច់មុខ ដោយត្រូវជំរុញឱ្យមានការថែទាំ ជួសជុលហេដ្ឋារចនាសម្ព័ន្ធនៅមជ្ឈមណ្ឌលឱ្យបានស្របតាមស្តង់ដារបច្ចេកទេស និងធានាឱ្យមានអនាម័យល្អប្រសើរជាងមុន។

៣-លើកទឹកចិត្តឱ្យមានការបង្កើតបន្ថែមនូវមជ្ឈមណ្ឌលបែងចែកផលនេសាទថ្មីដែលមានលក្ខណៈប្រកួតប្រជែងពេញលេញ និងផ្តល់ការបន្ទូរបន្ថយតម្រូវការទុនវិនិយោគ និងប្រាក់កក់ធានាកិច្ចសន្យារបស់វិនិយោគិន ទាំងទីតាំងរដ្ឋនិងទីតាំងឯកជន។ ចំណែកឯកម្រៃសេវារបស់អាជីវករ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវ។

៤-សហការផ្តល់ព័ត៌មាន/ទិន្នន័យឱ្យបានទូលំទូលាយ និងទាន់ពេលវេលាអំពីបរិមាណផ្គត់ផ្គង់ប្រភេទត្រីធម្មជាតិ និងត្រីចិញ្ចឹមក្នុងស្រុកតាមរដូវកាលបិទនិងបើកនេសាទទៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា សំដៅចាត់វិធានការទប់ស្កាត់ក្នុងន័យការពារប្រតិបត្តិការផលិតករក្នុងស្រុកឱ្យមានប្រសិទ្ធភាពខ្ពស់។

៥-ពង្រឹងការត្រួតពិនិត្យគុណភាព សុវត្ថិភាពផល ផលិតផលជលផលនាំចូលដើម្បីធានាសុខុមាលភាពសាធារណៈ ព្រមទាំងលើកទឹកចិត្តអាជីវករដែលកែច្នៃផល ផលិតផលជលផលក្នុងស្រុកឱ្យមានឈ្មោះ ស្លាកសញ្ញា និងបញ្ជាក់ពីប្រភព និងគុណភាពផល ផលិតផលជលផល។

ទទួលបានសារាចរណែនាំនេះ គ្រប់អង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទក្រសួង គ្រប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់ផ្សព្វផ្សាយ និងអនុវត្តតាមខ្លឹមសារនៃសារាចរណែនាំនេះ ដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តមកក្រសួងវិញ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- រដ្ឋបាលរាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- ថ្នាក់ដឹកនាំក្រសួង
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
- គ្រប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត
  "ដើម្បីជ្រាបនិងអនុវត្ត"
- ឯកសារ កាលប្បវត្តិ